## តារាងកម្មវិធីទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ដំណាក់កាល | ចំនួនលើក | ពេលវេលាទៅពិនិត្យសុខភាព |
|---|---|---|
| ដំណាក់កាលទី១ | ពិនិត្យផ្ទៃពោះលើកទី១ | មានគភ៌អាយុ<br>តិចជាង១២សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះលើកទី២ | មានគភ៌អាយុ<br>២០ទៅ២៤សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះលើកទី៣ | មានគភ៌អាយុ<br>៣០ទៅ៣២សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះលើកទី៤ | មានគភ៌អាយុ<br>៣៦ទៅ៣៨សប្តាហ៍ |
| ដំណាក់កាលទី២ | ពេលសម្រាលកូន | តាមភាពជាក់ស្តែង |
| ដំណាក់កាលទី៣ | ពិនិត្យសុខភាពក្រោយសម្រាលលើកទី១<br>( ពិនិត្យទាំងម្តាយ និងកូន ) | ថ្ងៃទី៧ក្រោយសម្រាល |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី២<br>( ពិនិត្យទាំងម្តាយ និងកូន ) | ថ្ងៃទី១៤ក្រោយសម្រាល |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៣<br>( ពិនិត្យទាំងម្តាយ និងកូន ) | កូនមានអាយុ១ខែកន្លះ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៤<br>( ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន ) | កូនមានអាយុ២ខែកន្លះ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៥<br>( ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន ) | កូនមានអាយុ៣ខែកន្លះ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៦<br>( ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន ) | កូនមានអាយុ៦ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៧<br>( ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន ) | កូនមានអាយុ៩ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៨<br>( ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន ) | កូនមានអាយុ១២ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី៩<br>( ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន ) | កូនមានអាយុ១៨ខែ |
| | ពិនិត្យសុខភាពក្រោយសម្រាលលើកទី១០<br>( ពិនិត្យសុខភាពនិងផ្តល់ថ្នាំបង្ការកូន ) | កូនមានអាយុ២៤ខែ |

## តារាងកម្មវិធីទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល<br>ករណីកូនរលូត កូនស្លាប់ពេលសម្រាល ម្តាយស្លាប់ពេលសម្រាល

| ដំណាក់កាល | ចំនួនលើក | ពេលវេលាទៅពិនិត្យសុខភាព |
|---|---|---|
| ពិនិត្យផ្ទៃពោះ | ពិនិត្យផ្ទៃពោះលើកទី១<br>គភ៌រលូត | មានគភ៌អាយុ<br>តិចជាង១២សប្តាហ៍ |
| | ពិនិត្យផ្ទៃពោះរួច<br>គភ៌រលូត | គភ៌អាយុ<br>១២សប្តាហ៍ក្រោម២៤សប្តាហ៍ |
| | ក្រោយរលូត<br>ពិនិត្យសុខភាពលើកទី២ | តាមការកំណត់របស់ពេទ្យ<br>លើកទី២( ចុងក្រោយ ) |
| កូនស្លាប់ពេលសម្រាល | កូនស្លាប់ពេលសម្រាល | តាមភាពជាក់ស្តែង |
| | ពិនិត្យសុខភាព<br>ក្រោយសម្រាលលើកទី១ | តាមការកំណត់របស់ពេទ្យ |
| | ពិនិត្យសុខភាព<br>ក្រោយសម្រាលលើកទី២ | តាមការកំណត់របស់ពេទ្យ |
| | ពិនិត្យសុខភាព<br>ក្រោយសម្រាលលើកទី៣ | តាមការកំណត់របស់ពេទ្យ<br>( ផ្តល់ជូនជាលើកចុងក្រោយ ) |
| ម្តាយស្លាប់ពេលសម្រាល | ពិនិត្យសុខភាពកូន<br>លើកទី១ | ថ្ងៃទី៧ក្រោយសម្រាល |
| | ពិនិត្យសុខភាពកូន<br>លើកទី២ | ថ្ងៃទី១៤ក្រោយសម្រាល |
| | ពិនិត្យសុខភាពកូន<br>លើកទី៣ | កូនមានអាយុ១ខែកន្លះ |
| | ពិនិត្យសុខភាពកូន<br>លើកទី៤ | កូនមានអាយុ២ខែកន្លះ |
| | ពិនិត្យសុខភាពកូន<br>លើកទី៥ | កូនមានអាយុ៣ខែកន្លះ |
| | ពិនិត្យសុខភាពកូន<br>លើកទី៦ | កូនមានអាយុ៦ខែ |
| | ពិនិត្យសុខភាពកូន<br>លើកទី៧ | កូនមានអាយុ៩ខែ |
| | ពិនិត្យសុខភាពកូន<br>លើកទី៨ | កូនមានអាយុ១២ខែ |
| | ពិនិត្យសុខភាពកូន<br>លើកទី៩ | កូនមានអាយុ១៨ខែ |
| | ពិនិត្យសុខភាពកូន<br>លើកទី១០( ចុងក្រោយ ) | កូនមានអាយុ២៤ខែ |

សំគាល់៖ សម្រាប់សមាជិក ប.ស.ស. ជាមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យា នៅពេលសម្រាលកូនពុំទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលពី ប.ស.ស. នោះទេ ។ សាមីខ្លួននឹងត្រូវទទួលបាន ប្រាក់ឧបត្ថម្ភមាតុភាពសម្រាប់ការសម្រាលកូនដូចមានចែងក្នុងអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ។



# កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភ

## របស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស.

# ជាស្ត្រីមានផ្ទៃពោះ និងកុមារ

## អាយុក្រោម ២ឆ្នាំ

**កម្មវិធីផ្តល់ប្រាក់**
**ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

## កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

### ក តើកម្មវិធីផ្តល់ប្រាក់របស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ផ្តល់ជូនទៅលើនរណាខ្លះ?

១ សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងនៅពេលសម្រាលកូន ដែលស្ថិតក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ និងមានសញ្ជាតិខ្មែរ

២ សមាជិក ប.ស.ស. ជាមន្ត្រីរាជការ ជាស្ត្រីមានផ្ទៃពោះ ក្នុងក្របខណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅតាមក្រសួង-ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

៣ សមាជិក ប.ស.ស. ជាមន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលបម្រើការងារនៅតាមក្រសួង-ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានការទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ



### ខ តើ សមាជិក ប.ស.ស. ត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភនេះ?

សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ មានសិទ្ធិចុះឈ្មោះដើម្បីទទួលប្រាក់ឧបត្ថម្ភលុះត្រាតែ

១ មានបណ្ណ សមាជិក ប.ស.ស. និងមានសុពលភាពប្រើប្រាស់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ


+


២ បានទៅទទួលសេវាសុខភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈតាមតារាងកម្មវិធីដែលសាមីខ្លួនទទួលបានពី ប.ស.ស.



៣ កុមារដែលម្តាយបានចុះឈ្មោះរួចក្នុងកម្មវិធីកុមារនោះត្រូវចូលក្នុងកម្មវិធីដោយស្វ័យប្រវត្តិដោយត្រូវភ្ជាប់មកជាមួយនូវបណ្ណសុខភាពកុមារ។



### គ តើ សមាជិក ប.ស.ស. ត្រូវភ្ជាប់ឯកសារអ្វីខ្លះ ដើម្បីដាក់ស្នើសុំប្រាក់ឧបត្ថម្ភនេះ?

សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះត្រូវអញ្ជើញមកកាន់ស្នាក់ការ/សាខា ប.ស.ស. ដែលនៅជិតបំផុតដើម្បីចុះឈ្មោះ ដោយត្រូវភ្ជាប់មកជាមួយនូវ៖

១ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ



២ បណ្ណសមាជិក ប.ស.ស.



៣ គណនីធនាគារ និងលេខទូរស័ព្ទ



គណនីធនាគារជាប្រាក់រៀល

៤ សៀវភៅសុខភាពមាតាបញ្ជាក់ពីអាយុគភ៌ដំបូងដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ



**សំគាល់៖** នៅពេលសមាជិក ប.ស.ស. ជាស្ត្រីមានគភ៌អាយុ៣៦ទៅ៣៨ សប្តាហ៍ ពិនិត្យផ្ទៃពោះរួច ត្រូវមកស្នាក់ការ/សាខា ប.ស.ស. ដើម្បីបំពេញទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភលើកទី៤ ដោយភ្ជាប់នូវ៖

១ បណ្ណសមាជិក ប.ស.ស.

២ សៀវភៅសុខភាពមាតាបញ្ជាក់ពីអាយុ៣៦ទៅ៣៨សប្តាហ៍របស់គភ៌ដែលចេញដោយមូលដ្ឋានសុខាភិបាលសាធារណៈ

កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល